# អនុក្រឹត្យ
# ស្តីពី
# ពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពើល្មើសនិងទឹកប្រាក់ពិន័យអន្តការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម វិធានការ និងកំណត់យន្តការគ្រប់គ្រងពិន័យអន្តរការណ៍ ក្នុងគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ និងសវនករ ដើម្បីធានាបាននូវប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ ÷

- សហគ្រាស ឬនីតិបុគ្គលដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និង/ឬ នៅអគ្គនាយកដ្ឋានពន្ធដារជាសហគ្រាសអ្នកជាប់ពន្ធធំនិងសហគ្រាសអ្នកជាប់ពន្ធមធ្យម
- គ្រប់អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបានចុះបញ្ជីជាមួយក្រសួង និងស្ថាប័នជំនាញ
- គ្រប់គណនេយ្យករ និងសវនករ ដែលជាសមាជិករបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា និងទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬ សវនកម្មពី **ន.គ.ស.**។

**មាត្រា ៣.-**

បច្ចេកសព្ទដែលប្រើប្រាស់នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់និយមន័យ ដូចខាងក្រោម ÷

- **ការមិនកាន់បញ្ជីគណនេយ្យ** សំដៅដល់ ការមិនរក្សាទុកឯកសារគណនេយ្យ និងការមិនកត់ត្រាប្រតិបត្តិការទាំងនោះចូលទៅក្នុងសៀវភៅ ឬបញ្ជីគណនេយ្យដែលបានកំណត់។ ឯកសារគណនេយ្យ មានជាអាទិ៍ វិក្កយ-បត្រ បង្កាន់ដៃបង់/ទទួលប្រាក់ សក្ខីបត្រចុះបញ្ជី ។ សៀវភៅ ឬបញ្ជីគណនេយ្យ មានជាអាទិ៍ សៀវភៅទិញ សៀវភៅលក់ សៀវភៅទទួលប្រាក់, សៀវភៅបង់ប្រាក់។
- **បុគ្គលល្មើស** សំដៅដល់ សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬគណនេយ្យករ ឬសវនករដែលប្រព្រឹត្តល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។
- **គណនេយ្យករ ឬ សវនករជារូបវន្តបុគ្គល** សំដៅដល់ សមាជិករបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជាដែលទទួលបានអាជ្ញាបណ្ណពី **ន.គ.ស.**។
- **គណនេយ្យករ ឬ សវនករជានីតិបុគ្គល** សំដៅដល់ ក្រុមហ៊ុនគណនេយ្យ ឬ ក្រុមហ៊ុនសវនកម្មដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពី **ន.គ.ស.**។
- **សហគ្រាសអ្នកជាប់ពន្ធធំ និងសហគ្រាសអ្នកជាប់ពន្ធមធ្យម** សំដៅដល់ សហគ្រាស ដែលត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- **ករណីមិនរាងចាល** សំដៅដល់ អំពើល្មើសដែលសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬ គណនេយ្យករ ឬសវនករ ធ្លាប់ទទួលរងពិន័យអន្តរការណ៍ ប៉ុន្តែនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល។
- **ម្ចាស់អាជ្ញាបណ្ណ** សំដៅដល់ បុគ្គលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម ពី **ន.គ.ស.**។
- **អំពើរាំងស្ទះ** សំដៅដល់ការប្រព្រឹត្តនូវអំពើណាមួយដោយបុគ្គលល្មើស ដែលមានជាអាទិ៍ ពុំបានផ្តល់កិច្ចសហការជាមួយមន្ត្រីនៃ **ន.គ.ស.** កំពុងអនុវត្តភារកិច្ច មិនអនុញ្ញាតឱ្យ **ន.គ.ស.** ធ្វើការពិនិត្យបញ្ជី

គណនេយ្យ ឬឯកសារគាំទ្រផ្សេងៗ កសាងឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំផ្សេងៗពាក់ព័ន្ធគណនេយ្យ មិនបានជូនដំណឹងទៅ **ន.គ.ស.** អំពីការផ្លាស់ប្តូរព័ត៌មានដែលបានចុះបញ្ជីរួច ជាដើម។

- **ការធ្វេសប្រហែសធ្ងន់ធ្ងរ** សំដៅដល់ ការមិនមានសៀវភៅណែនាំស្តីពីការធ្វើសវនកម្មដើម្បីធានានូវគុណភាព ឬការមិនមាននីតិវិធីសវនកម្មគ្រប់គ្រាន់ ឬ ការមិនបានបណ្តុះបណ្តាលត្រឹមត្រូវដល់អ្នកពាក់ព័ន្ធ ឬការមិនមានឯកសារភស្តុតាងសវនកម្មគ្រប់គ្រាន់ តាមតម្រូវការរបស់ស្តង់ដាការប្រកបវិជ្ជាជីវៈសវនកម្ម ឬ ការមិនផ្តោតការយកចិត្តទុកដាក់លើគុណភាពសវនកម្មពីថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន ឬកត្តាផ្សេងទៀតប្រហាក់ប្រហែល។
- **ការធ្វេសប្រហែស** សំដៅដល់ការមិនអនុលោមតាមស្តង់ដាសវនកម្ម និងស្តង់ដាពាក់ព័ន្ធជាធរមានដែលនាំឱ្យធ្លាក់ចុះគុណភាពសវនកម្ម ដែលមិនមែនការធ្លាក់ចុះដោយការធ្វេសប្រហែសធ្ងន់ធ្ងរ។

## ជំពូកទី ២
## អំពើល្មើស និងពិន័យអន្តរការណ៍
### ផ្នែកទី ១
### សម្រាប់សហគ្រាស

**មាត្រា ៤.-**

សហគ្រាសជាអ្នកជាប់ពន្ធធំត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

ក- ការមិនកាន់បញ្ជីគណនេយ្យ ត្រូវពិន័យជាប្រាក់ ២០.០០០.០០០(ម្ភៃលាន)រៀល។

ខ- ការមិនរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០(ដប់លាន)រៀល។

គ- ការមិនប្រើប្រាក់រៀលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០ (ពីរលាន)រៀល។

ឃ- ការមិនប្រើភាសាខ្មែរនៅក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ស្របតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០(ពីរលាន)រៀល។

ង- ការប្រើភាសាក្នុងឯកសារគាំទ្រខុសពីការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរងពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០(ពីរលាន) រៀល។

ច- ការមិនបានជូនដំណឹងមក **ន.គ.ស.** អំពីប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធ ត្រូវរងពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០(ពីរលាន) រៀល។

ឆ- ការប្រើការិយបរិច្ឆេទគណនេយ្យខុសពីច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដោយគ្មានការអនុញ្ញាត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២.០០០.០០០ (ពីរលាន)រៀល។

ជ- ការខកខានមិនដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០(ម្ភៃលាន)រៀល។

ឈ- ការមិនដាក់ ឬភាពយឺតយ៉ាវក្នុងដាក់របាយការណ៍ហិរញ្ញវត្ថុ មក **ន.គ.ស.** តាមពេលវេលាកំណត់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២០០.០០០(ម្ភៃម៉ឺន)រៀល ក្នុង១ថ្ងៃ។

ញ- ការយឺតយ៉ាវនៃការបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឯករាជ្យតាមពេលវេលាកំណត់ ត្រូវពិន័យជាប្រាក់ ៥០.០០០(ប្រាំម៉ឺន) រៀល ក្នុង១ថ្ងៃ។

ដ- ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន សម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០(ម្ភៃលាន)រៀល។

ឋ- ការមិនរក្សាទុកឯកសារគណនេយ្យតាមច្បាប់កំណត់ ត្រូវពិន័យជាប្រាក់ ១០.០០០.០០០(ដប់លាន)រៀល។

ឌ- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវរងពិន័យជាទឹកប្រាក់ ២.០០០.០០០(ពីរលាន)រៀល។

ឍ- ការមិនរក្សាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ដោយសហគ្រាសដែលបានរំលាយ ត្រូវរងពិន័យជាទឹកប្រាក់ ៥.០០០.០០០(ប្រាំលាន)រៀល។

**មាត្រា ៥.-**

សហគ្រាសជាអ្នកជាប់ពន្ធមធ្យមត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

ក- ការមិនកាន់បញ្ជីគណនេយ្យ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១៦.០០០.០០០(ដប់ប្រាំមួយលាន)រៀល។

ខ- ការមិនរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០ (ប្រាំបីលាន)រៀល។

គ- ការមិនប្រើប្រាក់រៀលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១.៥០០.០០០ (មួយលាន ប្រាំសែន)រៀល។

ឃ- ការមិនប្រើភាសាខ្មែរនៅក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១.៥០០.០០០ (មួយលានប្រាំសែន)រៀល។

ង- ការប្រើភាសាក្នុងឯកសារគាំទ្រខុសពីការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរងពិន័យអន្តរការណ៍ជាប្រាក់ ១.៥០០.០០០(មួយលាន ប្រាំសែន) រៀល។

ច- ការមិនបានជូនដំណឹងមក **ន.គ.ស.** អំពីប្រព័ន្ធគណនេយ្យកុំព្យូទ័រ ឬ/និង ប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធ ត្រូវរងពិន័យអន្តរការណ៍ជាប្រាក់ ១.៥០០.០០០(មួយលាន ប្រាំសែន) រៀល។

ឆ- ការប្រើវាក្យស័ព្ទបច្ចេកទេសគណនេយ្យខុសពីច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដោយគ្មានការអនុញ្ញាត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១.៥០០.០០០ (មួយលាន ប្រាំសែន)រៀល។

ជ- ការខកខានមិនដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១៦.០០០.០០០ (ដប់ប្រាំមួយលាន)រៀល។

ឈ- ការមិនដាក់ ឬភាពយឺតយ៉ាវក្នុងដាក់របាយការណ៍ហិរញ្ញវត្ថុ មក **ន.គ.ស.** តាមពេលវេលាកំណត់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១៥០.០០០ (ដប់ប្រាំម៉ឺន)រៀល ក្នុង១ថ្ងៃ។

ញ- ការយឺតយ៉ាវនៃការបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឯករាជ្យតាមពេលវេលាកំណត់ ត្រូវពិន័យជាប្រាក់ ៥០.០០០(ប្រាំម៉ឺន) រៀល ក្នុង១ថ្ងៃ។

ដ- ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន សម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១៦.០០០.០០០(ដប់ប្រាំលាន)រៀល។

ឋ- ការមិនរក្សាទុកឯកសារគណនេយ្យតាមច្បាប់កំណត់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០ (ប្រាំបីលាន) រៀល។

ឌ- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវរងពិន័យជាទឹកប្រាក់ ២.០០០.០០០(ពីរលាន)រៀល។

ឍ- ការមិនរក្សាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ដោយសហគ្រាសដែលបានរំលាយ ត្រូវរងពិន័យជាទឹកប្រាក់ ៣.០០០.០០០(បីលាន)រៀល។

## ផ្នែកទី ២
## សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

**មាត្រា ៦.-**

សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

ក- ការមិនកាន់បញ្ជីគណនេយ្យ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០(ប្រាំបីលាន)រៀល។

ខ- ការមិនរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៤.០០០.០០០ (បួនលាន)រៀល។

គ- ការមិនប្រើប្រាក់រៀលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៨០០.០០០ (ប្រាំបីសែន)រៀល។

ឃ- ការមិនប្រើភាសាខ្មែរនៅក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៨០០.០០០(ប្រាំបីសែន)រៀល។

ង- ការប្រើភាសាក្នុងឯកសារគាំទ្រខុសពីការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរងពិន័យអន្តរការណ៍ជាប្រាក់ ១.០០០.០០០(មួយលាន) រៀល។

ច- ការមិនបានជូនដំណឹងមក **ន.គ.ស.** អំពីប្រព័ន្ធគណនេយ្យកុំព្យូទ័រ ឬ និងប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធ ត្រូវរងពិន័យអន្តរការណ៍ជាប្រាក់ ១.០០០.០០០(មួយលាន) រៀល។

ឆ- ការប្រើការិយបរិច្ឆេទគណនេយ្យខុសពីច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដោយគ្មានការអនុញ្ញាត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៨០០.០០០(ប្រាំបីសែន)រៀល។

ជ- ការខកខានមិនដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៣.០០០.០០០(បីលាន)រៀល។

ឈ- ការមិនដាក់ ឬភាពយឺតយ៉ាវក្នុងដាក់របាយការណ៍ហិរញ្ញវត្ថុ មក **ន.គ.ស.** តាមពេលវេលាកំណត់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១០០.០០០(ដប់ម៉ឺន)រៀល ក្នុង១ថ្ងៃ។

ញ- ការយឺតយ៉ាវនៃការបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឯករាជ្យតាមពេលវេលាកំណត់ត្រូវពិន័យជាប្រាក់ ៥០.០០០(ប្រាំម៉ឺន) រៀល ក្នុង១ថ្ងៃ។

ដ- ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន សម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០(ប្រាំបីលាន)រៀល។

ឋ- ការមិនរក្សាទុកឯកសារគណនេយ្យតាមច្បាប់កំណត់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៨.០០០.០០០ (ប្រាំបីលាន)រៀល។

ឌ- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវរងពិន័យជាទឹកប្រាក់ ២.០០០.០០០(ពីរលាន)រៀល។

## ផ្នែកទី ៣
## សម្រាប់គណនេយ្យករ និងសវនករ

**មាត្រា ៧.-**

គណនេយ្យករជារូបវន្តបុគ្គល ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

ក- ប្រព្រឹត្តល្មើសទៅនឹងកថាខណ្ឌទី២ នៃមាត្រា ២៨ នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០(ដប់លាន)រៀល។

ខ- ការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យប្រចាំឆ្នាំ តាមពេលវេលាកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ម្ចាស់អាជ្ញាបណ្ណត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ ១០០.០០០(មួយសែន)រៀល ក្នុង ១(មួយ) ថ្ងៃ។

គ- ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណសវនកម្មតាមពេលវេលាកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១០០.០០០(មួយសែន)រៀល ក្នុង ១(មួយ)ថ្ងៃ។

**មាត្រា ៨.-**

គណនេយ្យករជានីតិបុគ្គល ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

ក- ការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យប្រចាំឆ្នាំ តាមពេលវេលាកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ម្ចាស់អាជ្ញាបណ្ណត្រូវទទួលរងពិន័យអន្តរការណ៍ ជាប្រាក់ ១៥០.០០០ (មួយសែនប្រាំម៉ឺន)រៀល ក្នុង ១(មួយ) ថ្ងៃ ។

ខ- ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណសវនកម្មតាមពេលវេលាកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១៥០.០០០(មួយសែនប្រាំម៉ឺន)រៀល ក្នុង ១(មួយ) ថ្ងៃ ។

គ- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវរងពិន័យជាទឹកប្រាក់ ៨.០០០.០០០(ប្រាំបីលាន)រៀល។

**មាត្រា ៩.-**

ចំពោះសវនករជារូបវន្តបុគ្គល ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

ក- ការរៀបចំរបាយការណ៍សវនកម្មដោយមិនប្រើភាសាខ្មែរ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល។

ខ- ការរៀបចំរបាយការណ៍សវនកម្មមិនស្របតាមស្តង់ដាទាក់ទងនឹងសវនកម្ម និងការអះអាងអន្តរជាតិនៃកម្ពុជា ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល។

គ- ការផ្តល់សេវាសវនកម្មជូនសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយមិនស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងកថាខណ្ឌទី១ នៃ មាត្រា ១៥ នៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០(ម្ភៃលាន)រៀល។

ឃ- ការផ្តល់សេវាកម្មជូនសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយមិនស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងកថាខណ្ឌទី២ នៃ មាត្រា ១៥ នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០(ម្ភៃលាន)រៀល។

ង- ការផ្តល់សេវាកម្មជូនសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយមិនស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងកថាខណ្ឌទី៣ នៃ មាត្រា ១៥ នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០(ម្ភៃលាន)រៀល។

ច- ការមិនរក្សាទុកភស្តុតាងសវនកម្មក្នុងរយៈពេលដប់ឆ្នាំយ៉ាងតិច ចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍សវនកម្ម ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០(ម្ភៃលាន)រៀល។

ឆ- ការប្រព្រឹត្តល្មើសទៅនឹងកថាខណ្ឌទី២ នៃមាត្រា ២៨ នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០(ម្ភៃលាន)រៀល។

ជ- ការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណសវនកម្មប្រចាំឆ្នាំ តាមពេលវេលាកំណត់ក្នុងបទប្បញ្ញត្តិជាធរមានត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១៥០.០០០(មួយសែនប្រាំម៉ឺន)រៀល ក្នុង ១(មួយ) ថ្ងៃ។

ឈ- ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណសវនកម្មតាមពេលវេលាកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១៥០.០០០(មួយសែនប្រាំម៉ឺន)រៀល ក្នុង ១(មួយ) ថ្ងៃ។

**មាត្រា ១០.-**

ចំពោះសវនករជានីតិបុគ្គល ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំពោះបទល្មើសដូចខាងក្រោម÷

ក- ការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណសវនកម្មប្រចាំឆ្នាំ តាមពេលវេលាកំណត់ក្នុងបទប្បញ្ញត្តិជាធរមានត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២០០.០០០ (ពីរសែន)រៀល ក្នុង ១ (មួយ) ថ្ងៃ

ខ- ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណសវនកម្មតាមពេលវេលាកំណត់ក្នុងបទប្បញ្ញត្តិជាធរមានត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២០០.០០០(ពីរសែន)រៀល ក្នុង១(មួយ) ថ្ងៃ។

គ- ការផ្តល់សេវាសវនកម្មជូនសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយមិនស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា ១៥ នៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០(ម្ភៃលាន)រៀល។

ឃ- ការផ្តល់សេវាកម្មជូនសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយមិនស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា ១៥ នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០(ម្ភៃលាន)រៀល។

ង- ការផ្តល់សេវាសវនកម្មជូនសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយមិនស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងកថាខណ្ឌទី៣ នៃមាត្រា១៥ នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៣០.០០០.០០០(សាមសិបលាន)រៀល។

ច- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវរងពិន័យជាទឹកប្រាក់ ១០.០០០.០០០(ដប់លាន)រៀល។

ឆ- ការមិនអនុលោមតាមស្តង់ដាសវនកម្ម និងស្តង់ដាពាក់ព័ន្ធជាធរមាន នាំឱ្យធ្លាក់ចុះគុណភាពសវនកម្មផ្អែកលើលទ្ធផលនៃការចុះត្រួតពិនិត្យ នឹងត្រូវទទួលរងទោសទណ្ឌដូចខាងក្រោម÷

ឆ-១-ការធ្វេសប្រហែសក្នុងការអនុលោមតាម ឬការបំពេញការងារសវនកម្មរបស់ក្រុមហ៊ុនសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២០.០០០.០០០(ម្ភៃលាន) រៀល។

ឆ-២-ការធ្វេសប្រហែសធ្ងន់ធ្ងរក្នុងការអនុលោមតាម ឬការបំពេញការងារសវនកម្មរបស់ក្រុមហ៊ុនសវនកម្ម ត្រូវទទួលរងពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៤០.០០០.០០០(សែសិបលាន) រៀល។

កម្រិតនៃការធ្លាក់ចុះគុណភាពសវនកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## ជំពូកទី ៣

## ករណីមិនរាងចាល និងការយឺតយ៉ាវមិនបានបង់ប្រាក់ពិន័យតាមកាលកំណត់

**មាត្រា ១១.-**

ក្នុងករណីបុគ្គលល្មើស ធ្លាប់ទទួលរងពិន័យអន្តរការណ៍ម្តងហើយ ប៉ុន្តែនៅបន្តប្រព្រឹត្តអំពើល្មើសដដែលបុគ្គលល្មើសនោះត្រូវទទួលរងការពិន័យអន្តរការណ៍បន្ថែមជាប្រាក់ដូចខាងក្រោម÷

- មិនរាងចាលលើកទី១ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍គុណនឹងពីរដង នៃប្រាក់ពិន័យអន្តរការណ៍ដែលបង់លើកដំបូង
- មិនរាងចាលលើកទី២ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍គុណនឹងពីរដង នៃប្រាក់ពិន័យអន្តរការណ៍ដែលបង់ក្នុងករណីមិនរាងចាលលើកទី១
- មិនរាងចាលលើកទី៣ ដែលប្រព្រឹត្តដោយសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ **ន.គ.ស.** នឹងរៀបចំលិខិតស្នើសុំទៅក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តវិធានការជាធរមានលើសហគ្រាស ឬលើអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបានបំពាន។

- មិនរាងចាលលើកទី៣ ដែលប្រព្រឹត្តដោយគណនេយ្យករនិងសវនករ **ន.គ.ស.** នឹងសម្រេចព្យួរ ឬដកហូត អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ឬ អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម។

**មាត្រា ១២.-**

ក្នុងករណីបុគ្គលល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវដំឡើងជាពីរដង។ ករណីការខកខានលើសពី ៦០ (ហុកសិប) ថ្ងៃ ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នេះនឹងត្រូវដំឡើងជាបីដង។ ករណីបើផុតរយៈពេល៩០ (កៅសិប) ថ្ងៃ **ន.គ.ស.** នឹងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

រយៈពេល៣០(សាមសិប)ថ្ងៃ ៦០(ហុកសិប)ថ្ងៃ និង៩០(កៅសិប)ថ្ងៃ ចាប់គិតពីថ្ងៃបុគ្គលល្មើសទទួលបានលិខិតជូនដំណឹងអំពីការបង់ប្រាក់ពិន័យអន្តរការណ៍ពី **ន.គ.ស.**។

## ជំពូកទី ៤

## ស្ថាប័នមានសមត្ថកិច្ច យន្តការនៃការពិន័យអន្តរការណ៍ និងការគ្រប់គ្រងប្រាក់ពិន័យ

**មាត្រា ១៣.-**

ការពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ **ន.គ.ស.**។ អគ្គនាយកនៃ **ន.គ.ស.** ជាអ្នកមានសិទ្ធិសម្រេចលើពិន័យអន្តរការណ៍និងវិធានការពាក់ព័ន្ធផ្សេងទៀត។

**ន.គ.ស.** មានសិទ្ធិចុះត្រួតពិនិត្យដល់ទីតាំងអាសយដ្ឋានរបស់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ ក្រុមហ៊ុនគណនេយ្យ ឬ ក្រុមហ៊ុនសវនកម្ម ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យអនុលោមភាពនៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន និងការត្រួតពិនិត្យគុណភាពសវនកម្ម។ អគ្គនាយកនៃ **ន.គ.ស.** ជាអ្នកមានសិទ្ធិសម្រេចលើការងារនេះ។

**មាត្រា ១៤.-**

បែបបទ និងនីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ដែលបានមកពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ទឹកប្រាក់ពិន័យអន្តរការណ៍ ជាកម្មវត្ថុនៃចំណូលថវិកាជាតិរបស់ **ន.គ.ស.** លើកលែងតែមានការសម្រេចដោយឡែករបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សានៃ **អ.ស.ហ.**។

**មាត្រា ១៥.-**

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីបុគ្គលល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ឬ បានរាំងស្ទះដល់ការបំពេញមុខងារនិងភារកិច្ចរបស់ **ន.គ.ស.** អគ្គនាយកនៃ **ន.គ.ស.** អាចអនុវត្តវិធានការមួយ ឬច្រើនដូចខាងក្រោម÷

- អញ្ជើញម្ចាស់សហគ្រាសដោយការផ្សព្វផ្សាយជាសាធារណៈ ដោយទុករយៈពេល៣០ថ្ងៃ ឱ្យម្ចាស់សហគ្រាសនោះចូលខ្លួនមកបំភ្លឺ ឬដោះបន្ទុក ឬ/និង
- ស្នើទៅក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង/ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់វិធានការ។ ក្នុងករណីនេះ ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង/ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់កិច្ចសហការជាមួយ **ន.គ.ស.** ក្នុងការបំពេញមុខងារ និងភារកិច្ចឱ្យមានប្រសិទ្ធភាពខ្ពស់ ឬ/និង
- កសាងនិងបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច។

មន្ត្រីមានសមត្ថកិច្ចរបស់ ន.គ.ស. ដែលមានចេតនាបិទបាំងអំពើល្មើសរបស់បុគ្គលល្មើស ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាលដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី ៥
## បណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចពិន័យអន្តរការណ៍

**មាត្រា ១៦.-**

ក្នុងករណីដែលបុគ្គលទទួលរងពិន័យមិនពេញចិត្តនឹងសេចក្តីសម្រេចពិន័យអន្តការណ៍ ដែលចេញដោយអគ្គនាយកនៃ ន.គ.ស. បុគ្គលនោះមានសិទ្ធិដាក់ពាក្យប្តឹងតវ៉ាទៅអគ្គនាយកនៃ ន.គ.ស. ដោយត្រូវបញ្ជាក់អំពីហេតុផលនៃការមិនពេញចិត្តលើសេចក្តីសម្រេចពិន័យអន្តរការណ៍។ អគ្គនាយកនៃ ន.គ.ស. ត្រូវឆ្លើយតបទៅម្ចាស់បណ្តឹង ក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែល ន.គ.ស. បានទទួលពាក្យបណ្តឹង។

ក្នុងករណីដែលបុគ្គលទទួលរងពិន័យនៅតែមិនពេញចិត្តនឹងសេចក្តីសម្រេចពិន័យអន្តការណ៍ ដែលចេញដោយអគ្គនាយកនៃ ន.គ.ស. បុគ្គលនោះមានសិទ្ធិដាក់ពាក្យបណ្តឹងទៅប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងរយៈពេល៣០(សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលបុគ្គលនោះបានទទួលសេចក្តីសម្រេចចំពោះពិន័យអន្តការណ៍។ ក្នុងរយៈពេល៩០ ថ្ងៃ ក្រោយពីកាលបរិច្ឆេទទទួលបានពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សា អ.ស.ហ. ត្រូវផ្តល់ការឆ្លើយតបទៅម្ចាស់បណ្តឹងអំពីការសម្រេចរបស់ខ្លួន។

ក្នុងករណី បុគ្គលនោះនៅតែមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បុគ្គលនោះអាចប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៣០(សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលបុគ្គលនោះទទួលសេចក្តីសម្រេចរបស់ប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

បណ្តឹងរបស់បុគ្គលដែលទទួលរងពិន័យអន្តការណ៍ទៅតុលាការ ពុំមានអនុភាពផ្អាកការអនុវត្តសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឡើយ។ ឳ

**មាត្រា ១៧.-**

វិធាននិងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ា ចំពោះសេចក្តីសម្រេចពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**មាត្រា ១៨.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការអនុវត្តអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ១៩.-**

អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសទាំងស្រុងដោយអនុក្រឹត្យនេះ។

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងជាប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រដ្ឋមន្ត្រីគ្រប់ក្រសួង អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និងប្រធាននៃគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ខែ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជា ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ